ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

ការបង្កើតនាយកដ្ឋាននេះ ក្នុងទិសដៅផ្តល់សេវាឯកទេសក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជននិងអនីតិជនតាមនីតិវិធីច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិនានា ។



www.pheakdeylaw.com

## ជំពូកទី២
## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា២.-**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៣.-**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានការិយាល័យមួយចំនួនចំណុះ ។

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងមន្ត្រីរបស់ការិយាល័យចំណុះនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ "

## ជំពូកទី៣
## អំពីសមត្ថកិច្ច និងភារកិច្ច

**មាត្រា៤.-**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនមានសមត្ថកិច្ច និងភារកិច្ច ដូចខាងក្រោម :

- ផ្ដើមយោបល់លើកឡើងនូវគោលការណ៍ ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជន និងកាមសាស្ត្រលើកុមារ ( អំពើអនាចារលើកុមារ ) ។
- ចាប់ខ្លួនចារី សហចារី ដកហូតសំភារៈ វត្ថុតាងពាក់ព័ន្ធកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។
- អនុវត្តតាមសាលក្រម សាលដីការបស់តុលាការពាក់ព័ន្ធករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ លើនីតិជន និងអនីតិជន ។
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដើម្បីកសាងផែនការយុទ្ធសាស្ត្រ និងសកម្មភាពក្នុងការប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន និងអនីតិជន ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដើម្បីស្វែងរកការផ្ដល់ជំនួយឯកទេស ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជនក្នុងប្រទេស និងសកម្មភាពឆ្លងដែន ។
- សិក្សាស្រាវជ្រាវស្ដីពីការលំបាក និងងាយស្រួលក្នុងនីតិវិធីប្រតិបត្តិរបស់នគរបាលចំណុះនាយកដ្ឋាន និងតាមស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។



www.pheakdeylaw.com

- សម្របសម្រួលលើការអនុវត្តច្បាប់ ដោយទំនាក់ទំនងជាមួយព្រះរាជអាជ្ញាតុលាការ ដែលពាក់ព័ន្ធដល់ការងារ និងសកម្មភាពប្រតិបត្តិការរបស់នាយកដ្ឋាន ។

- គ្រប់គ្រង និងផ្តល់ពត៌មាន ពីមុខសញ្ញាក្នុងប្រទេស និងមុខសញ្ញាឧក្រិដ្ឋអន្តរជាតិ ដែលពាក់ព័ន្ធសកម្មភាពការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ លើនីតិជន និងអនីតិជន ។

- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការនគរបាលជាតិ ។

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្មារតី និងកិត្តិយសរបស់នគរបាលជាតិ ។

- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។

- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់អោយ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសាផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com